**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចព្រមព្រៀង**

**រវាង**

**រោងចក្រ ជុវ៉ា (ខេមបូឌា) ខូអិលធីឌី**

**និង**

**តំណាងប្រតិភូបុគ្គលិកប្រចាំ**

**រោងចក្រ ជុវ៉ា (ខេមបូឌា) ខូអិលធីឌី**

**ស្តីអំពីការព្យួរកិច្ចសន្យាការងារ**

នៅថ្ងៃទី១៥ខែមេសា ឆ្នាំ២០២០ វេលាម៉ោង ០២រសៀល នៅក្នុងរោងចក្រ **ជុវ៉ា (ខេមបូឌា) ខូអិលធីឌី**មានកិច្ចប្រជុំមួយ រវាងតំណាងក្រុមហ៊ុន និង តំណាងកម្មករនិយោជិតប្រចាំរោងចក្រ ។ នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រដោយសារតែក្រុមហ៊ុនយើងអ្នកបញ្ជាទិញលុបចោលការបញ្ជាទិញ ដែលធ្វើអោយក្រុមហ៊ុនយើងមិនមានទំនិញធ្វើអាស្រ័យហេតុដូចនេះក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងារ របស់កម្មករ និយោជិតទាំងអស់រយៈពេលចំនួន**១ខែ** គឺចាប់ពី**ថ្ងៃទី២០ខែមេសា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី ២០ខែ ឧសភា ឆ្នាំ២០២០**នៅក្នុងអំឡុងពេលនៃការព្យួរការងារនេះកម្មករ និយោជិតបានឯកភាពទទួលយកនូវប្រាក់ឈ្នួលចំនួន ៣០ ដុល្លា ក្នុង១ខែ សម្រាប់កម្មករ និយោជិតម្នាក់ៗ ពីក្រុមហ៊ុន។

អង្គប្រជុំបានចប់វេលាម៉ោង ០៣ រសៀលនាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងពីរមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន។

កំពង់ឆ្នាំង.ថ្ងៃទី១៥ ខែមេសា ឆ្នាំ ២០២០

**នាយកក្រុមហ៊ុន**

CHUWA (CAMBODIA) Co.,Ltd.
KINGDOM OF CAMBODIA

**សហជីព និង តំណាងកម្មករ**